ព្រះរាជាណាចក្រកម្ពុជា

ជាតិ  សាសនា  ព្រះមហាក្សត្រ

ទីស្តីការគណៈរដ្ឋមន្ត្រី

# ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ក.ស.វ.)

## ECONOMIC, SOCIAL AND CULTURAL COUNCIL (ECOSOCC)








# របាយការណ៍វិភាគស្ថានភាព
# សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងបរិស្ថាន
# ប្រចាំឆ្នាំ២០២៥

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ទីស្តីការគណៈរដ្ឋមន្ត្រី**

**ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌**

**លេខ៖ ១២ របក. ក.ស.វ.**

ថ្ងៃសុក្រ ៨រោច ខែចេត្រ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែមេសា ឆ្នាំ២០២៦

# របាយការណ៍
# ស្តីពី
# ការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងបរិស្ថានកម្ពុជា ប្រចាំឆ្នាំ២០២៥*

ក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ (ក.ស.វ.) បានធ្វើការវិភាគស្ថានភាពសេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ និងបរិស្ថានរបស់កម្ពុជាប្រចាំឆ្នាំ២០២៥ ដោយផ្អែកលើទិន្នន័យព័ត៌មាន ដែលទទួលបានពីក្រសួង ស្ថាប័នពាក់ព័ន្ធ ព្រមទាំងមតិយោបល់ ដែលជាធាតុចូលពីកិច្ចប្រជុំទូលាយរបស់ក.ស.វ. ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងកិច្ចប្រជុំចង្អៀតផ្សេងទៀត របស់ក.ស.វ. ដោយឈរលើគោលការណ៍បរិយាបន្ននៃសេចក្តីវិនិច្ឆ័យ ដែលមានខ្លឹមសារ ដូចខាងក្រោម៖

## ១)ស្ថានភាពសន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ និងអត្រាប្តូរប្រាក់ (តារាងទី១)

អតិផរណាឆ្នាំ២០២៥ មានអត្រាស្មើនឹង ២,៥% ក្នុងនោះក្រុមទំនិញទាំង១២ មានអត្រាអតិផរណាផ្សេងគ្នា ដូចក្នុងតារាងខាងក្រោម (សម្រាប់ឆ្នាំ ២០២៥ និងឆ្នាំ២០២៤)។

តារាង ១.១. បម្រែបម្រួលសន្ទស្សន៍ថ្លៃតាមក្រុមទំនិញ

| ល.រ. | ក្រុមទំនិញ | អតិផរណាឆ្នាំ២០២៥, % | អតិផរណាឆ្នាំ២០២៤, % |
|---|---|---|---|
| | ទំនិញប្រើប្រាស់ (២៥៩ មុខ) | ២,៥ | ០,៨ |
| ១ | សម្លៀកបំពាក់ និងស្បែកជើង | ៥,៤ | ២,៨ |
| ២ | ម្ហូបអាហារ | ៣,៧ | ១,២ |
| ៣ | ការសិក្សា | ២,៩ | ២,៥ |
| ៤ | ទំនិញនិងសេវាកម្មផ្សេងៗ | ២,៦ | ០,៧ |
| ៥ | ភេសជ្ជៈមានជាតិស្រវឹងនិងថ្នាំជក់ | ២,៣ | -០,១ |

* ការវិភាគជាសំណេរដកស្រង់ចេញពីទិន្នន័យសំខាន់ៗប៉ុណ្ណោះ មិនគ្របដណ្តប់តួលេខទាំងអស់ទេ (មើលតារាងភ្ជាប់មកជាមួយ)។

* ដើម្បីមានសង្គតិភាពក្នុងការប្រើប្រាស់លេខខ្មែរនិងអន្តរជាតិ សញ្ញាក្បៀសនៅក្នុងអត្ថបទ តាងឱ្យទសភាគ។ ប៉ុន្តែក្នុងតារាងលេខ (Excel) សញ្ញាក្បៀសតាងឱ្យខ្ទង់ពាន់ ឯសញ្ញាចុចជាទសភាគវិញ។ សម្គាល់ [YoY] = ធៀបនិងឆ្នាំមុន។

| | | | |
|---|---|---|---|
| ៦ | ការកម្សាន្ត និងវប្បធម៌ | ២,៣ | ០,៤ |
| ៧ | គ្រឿងសង្ហារិម និងសម្ភារៈប្រើប្រាស់ | ២,០ | ០,៨ |
| ៨ | លំនៅឋាន ទឹក អគ្គិសនី ឧស្ម័ន និងឥន្ទនៈផ្សេងៗ | ២,០ | ០,២ |
| ៩ | ភោជនីយដ្ឋាន | ១,២ | ០,៣ |
| ១០ | ទូរគមនាគមន៍ | ០,២ | -០,១ |
| ១១ | សុខាភិបាល | -១,០ | ១,៦ |
| ១២ | ដឹកជញ្ជូន | -២,៧ | -១,៣ |
| | ក្នុងនោះប្រេងសាំង | -៧,៦ | -៦,៣ |

*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិក្រសួងផែនការ ,*

គួរកត់សម្គាល់មុខទំនិញដែលឡើងថ្លៃខ្ពស់ គឺបន្លែ ៥,៦% និងផ្លែឈើ ៥,០%។

តារាង១.២. អតិផរណាប្រចាំខែ ឆ្នាំ២០២៣-២០២៥ ( កំណើនថ្លៃទំនិញធៀបនឹងខែដូចគ្នាឆ្នាំមុន )

| ឆ្នាំ | ធៀបនឹងខែ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ | ប្រចាំឆ្នាំ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| ២០២៥ | ដូចគ្នាឆ្នាំមុន | ៦,០% | ៤,៧% | ៣,៧% | ៣,១% | ១,៧% | ១,៦% | ១,៧% | ១,៨% | ១,៩% | ១,៧% | ១,៣% | ១,២% | ២,៥% |
| | មុន | ០,៣% | -០,៦% | -០,៥% | ០,៤% | -០,៦% | -០,១% | ០,៤% | ០,៦% | ០,៦% | ០,៥% | -០,៥% | ០,៦% | |
| ២០២៤ | ដូចគ្នាឆ្នាំមុន | -២,៥% | ០,៧% | ០,២% | ០,៥% | ០,៨% | ០,៧% | ០,៦% | ០,៣% | ០,៨% | ១,៤% | ២,០% | ៣,០% | ០,៨% |
| | មុន | -០,៥% | -០,៣% | ០,៥% | ១,០% | ១,១% | ០,០១% | ០,៤% | ០,៥% | ០,៥% | ០,៧% | -០,០៤% | ០,៧% | |
| ២០២៣ | ដូចគ្នាឆ្នាំមុន | ០,៣% | ២,២% | ០,៧% | ១,១% | ០,៥% | ០,១% | ១,៩% | ៣,២% | ៣,៨% | ៣,៩% | ២,៧% | ៣,២% | ២,២% |
| | មុន | ០,៧% | ០,៥% | ០,១% | ០,៥% | ០,២% | ០,៤% | ០,៤% | ០,៩% | ០,០២% | ០,១% | -០,៦% | ០,១% | |

*ប្រភព៖ វិទ្យាស្ថានជាតិស្ថិតិក្រសួងផែនការ ,*

**អត្រាប្តូរប្រាក់**: ជារួមអត្រាប្តូរប្រាក់មានស្ថិរភាព។ ប្រាក់រៀលមានការឡើងថ្លៃធៀបនឹងប្រាក់ដុល្លារ។

តារាង១.៣: អត្រាប្តូរប្រាក់

| ប្រភេទ | ឆ្នាំ២០២៥ | ឆ្នាំ២០២៤ | បម្រែបម្រួល |
|---|---|---|---|
| **៛/១ដុល្លារ** | ៤ ០១៣៛ | ៤ ០២៥៛ | -០,៣% |
| **៛/១បាត** | ១២៧៛ | ១១៨៛ | +៧,៦% |
| **៛/១ដុង** | ០,១៥៣៛ | ០,១៥៨៛ | -៣,២% |
| **៛/១យ៉ន់** | ៥៧៤៛ | ៥៥១៛ | +៤,២% |
| **៛/១អឺរ៉ូ** | ៤ ៧២៤៛ | ៤ ១៩២៛ | +១២,៧% |

*ប្រភព៖ ធនាគារជាតិនៃកម្ពុជា*

## ២ ) ស្ថានភាពថវិកាជាតិ ( តារាងទី២ )

យោងតាមស្ថិតិដែលឆ្លងរតនាគារជាតិ ចំណូលថវិកាជាតិក្នុងឆ្នាំ២០២៥ អនុវត្តបាន ២៩ ១៧៣,៤ ប៊ីលានរៀល (៧ ២៦៩,៧ លានដុល្លារ) ត្រូវនឹង ១០២,៤% នៃផែនការ។ ក្នុងនោះចំណូលចរន្ត ២៨ ៥៣៣,៣ ប៊ីលានរៀល (៧ ១១០,២ លានដុល្លារ) ត្រូវនឹង១០២,៤% នៃផែនការ និងចំណូលមូលធន ៦៤០,១ប៊ីលានរៀល (១៥៩,៥ លានដុល្លារ) ត្រូវនឹង ១០៤,៨%នៃផែនការ។ បើធៀបនឹងឆ្នាំ២០២៤ ចំណូលថវិកាជាតិកើនឡើង១១,៧% ក្នុងនោះចំណូលចរន្តកើនឡើង១០,៩%

និងចំណូលមូលធន កើនឡើង៦២,២%។

⇨ចំណូលចរន្តកើនឡើង ដោយសារបន្ទុកណាលមកពីចំណូលសារពើពន្ធកើនឡើង១០,៤% និងចំណូលមិនមែនសារពើពន្ធកើនឡើង ១៤,៨%។

តារាង២.១. ចំណូលសារពើពន្ធ ឆ្នាំ២០២៥

| មុខចំណូល | ធៀបនឹងផែនការ | %Δធៀបនឹងឆ្នាំ២០២៤ | មុខចំណូល | ធៀបនឹងផែនការ | %Δធៀបនឹងឆ្នាំ២០២៤ |
|---|---|---|---|---|---|
| **ចំណូលសារពើពន្ធ** * | ១០២,៨% | +១០,៤% | **ចំណូលមិនមែនសារពើពន្ធ*** | ៩៩,៩% | +១៤,៨% |
| ✓**ពន្ធ និងអាករគយ** ** | — | +២០,៧% | ✓កាស៊ីណូ | ១៣៤,៥% | +១៤,៩% |
| –ពន្ធគយ (របបនាំចូល) | — | +៤,០% | ✓ អាជ្ញាបណ្ណក្នុងស្រុក | ៣២៥,៦% | +៤៣,៧% |
| –អាករពិសេសលើរបបនាំចូល | — | +៣៣,៧% | ✓ គ្រប់គ្រងនិងទិដ្ឋាការនាំចេញ | ១១០,៨% | -២,៨% |
| –អាករលើតម្លៃបន្ថែមរបបនាំចូល | — | +១៨,៧% | ✓ វត្ថុប្រមាញ់ | ១២៧,៤% | +១១៨,២% |
| –អាករនាំចេញ | — | +៤៥,០% | ✓សម្បទានរ៉ែ | ៨៥,៥% | +២៧,០% |
| –អាករបន្ថែមលើតេលសិលា | — | -០,៤% | ✓អាកាសចរណ៍ស៊ីវិល | ៨៩,៦% | +២១,៦% |
| ✓**ចំណូលពន្ធដារ** *** | ៨៤,៥% | +១,៨% | ✓ផលទុនទេសចរណ៍ | ៥៦,២% | -៩,១% |
| –ពន្ធលើប្រាក់បៀវត្ស | ៩០,២% | +៣,៤% | ✓ជួលរោងចក្រសហគ្រាសសម្ភារៈ | ១០៦,៨% | +៧,១% |
| – ពន្ធលើប្រាក់ចំណូល | ៨៥,៥% | +៣,៧% | ✓ប្រៃសណីយ៍និងទូរគមនាគមន៍ | ៩៨,៦% | +៤,៩% |
| – អាករលើតម្លៃបន្ថែម | ៩២,៧% | +៦,៣% | ✓ត្រួតពិនិត្យគុណភាពផលិតផល | ១៣៥,៦% | |
| –អាករពិសេស | ៤៧,៣% | -២៣,៣% | | | |
| –ពន្ធថវិកាខេត្ត-រាជធានី | ៨៧,៥% | +០,០១% | | | |

* តួលេខរតនាគារជាតិ **តួលេខអគ្គនាយកដ្ឋានគយនិងរដ្ឋាករ ***តួលេខអគ្គនាយកដ្ឋានពន្ធដារ

ចំណាយថវិកាជាតិក្នុងឆ្នាំ២០២៥ អនុវត្តបាន ២៨ ៦៦៥,៨ ប៊ីលានរៀល(៧ ១៤៣,២ លានដុល្លារ) ស្មើនឹង១០០,៥% នៃផែនការ ក្នុងនោះចំណាយចរន្ត ២៤ ៤២៣,៣ប៊ីលានរៀល(៦ ០៨៦,១ លានដុល្លារ) ស្មើនឹង១០២,២%នៃផែនការ និងចំណាយមូលធន ៤ ២៤២,៥ ប៊ីលានរៀល(១ ០៥៧,២ លានដុល្លារ) ស្មើនឹង៩១,៧% នៃផែនការ។ បើធៀបនឹងឆ្នាំមុន ចំណាយថវិកាជាតិកើនឡើង១៣,២% ក្នុងនោះចំណាយចរន្តកើនឡើង១៣,៤% និងចំណាយមូលធនកើនឡើង១២,៣%។

ជាលទ្ធផល ថវិកាជាតិនាឆ្នាំ២០២៥មានអតិរេកចំនួន៥០៧,៦ ប៊ីលានរៀល(១២៦,៥ លានដុល្លារអាម៉េរិក)។ គួរកត់សម្គាល់ថាតួលេខចំណាយមូលធនក្នុងតារាងទិន្នន័យឆ្លុះបញ្ចាំងតែចំណាយដែលឆ្លងរតនាគារជាតិតែប៉ុណ្ណោះ។

## ៣) ស្ថានភាពរូបិយវត្ថុ (តារាងទី៣)

➢ សូចនាកររូបិយវត្ថុ : *M2* មានចំនួន ២៥៦ ៧៨០,៦ ប៊ីលានរៀល កើនឡើង ១២,៩% [YoY]។

សមាសធាតុរូបិយវត្ថុខែធ្នូឆ្នាំ២០២៥ (%នៃរូបិយវត្ថុ *M2*)




សមាសធាតុរូបិយវត្ថុខែធ្នូឆ្នាំ២០២៤




□ រូបិយវត្ថុក្រៅគ្រឹះស្ថានទទួលប្រាក់បញ្ញើ (រ) □ ប្រាក់បញ្ញើចរន្ត □ ប្រាក់បញ្ញើផ្សេងទៀត

តារាង៣.១. កំណើនសូចនាកររូបិយវត្ថុ ២០២១-២០២៥ ធៀបនឹងឆ្នាំមុន

| | ២០២១ | ២០២២ | ២០២៣ | ២០២៤ | ២០២៥ |
|---|---|---|---|---|---|
| *M2* | +១៦,៣% | +៨,៣% | +១២,៥% | +១៧,៥% | +១២,៩% |
| *សមាមាត្រ M2 ក្នុងផសស* | +១៣៦,០% | +១៤២,១% | +១៤៨,០% | +១៥៩,១% | +១២៤,៤% |
| *M1* | +១៥,៣% | -៧,៧% | +៣,៨% | +១៥,៨% | +២២,៧% |
| *សមាមាត្រ M1 ក្នុងផសស* | ៣៨,៣% | ៣៤,២% | ៣២,៨% | ៣៤,៧% | ២៩,៥% |
| រូបិយវត្ថុក្រៅគ្រឹះស្ថានទទួលប្រាក់បញ្ញើ | +៨,៣% | -៣,១% | +៥,៩% | -២,៨% | +២២,៥% |
| ប្រាក់បញ្ញើចរន្ត | +១៨,៩% | -៩,៩% | +២,៧% | +២៥,៨% | +២២,៩% |
| ប្រាក់បញ្ញើផ្សេងទៀត | +១៦,៧% | +១៤,៦% | +១៥,៣% | +១៨,០% | +១០,១% |
| ប្រាក់បញ្ញើជារូបិយបណ្ណ | +១៥,០% | +៨,៤% | +១៣,០% | +១៩,៩% | +១២,១% |

*ប្រភព៖ ធនាគារជាតិនៃកម្ពុជា*

ក្នុងឆ្នាំ២០២៥ រូបិយវត្ថុទូទៅ*M2*មានចំនួនប្រហែល ១២៤,៤%នៃផសស ប៉ុន្តែ**សមមាត្រ***M1*ក្នុងផសស មានត្រឹមតែ ២៩,៥% ប៉ុណ្ណោះ។

ទុនបំរុងជារូបិយប័ណ្ណបរទេសដុលមានចំនួន២៧ ៥២៩,៩ លានដុល្លារអាម៉េរិកកើនឡើង ២២,៣%[YoY]។

តារាង៣.២. អត្រាការប្រាក់ប្រចាំឆ្នាំ:

| *ប្រភេទអត្រាការប្រាក់* | *អត្រាឆ្នាំ ២០២៣* | *អត្រាឆ្នាំ ២០២៤* | *អត្រាឆ្នាំ ២០២៥* |
|---|---|---|---|
| បញ្ញើជារៀលនៅធនាគារពាណិជ្ជ | ៦,៥% | ៥,១% | ៤,៦% |
| កម្ចីជារៀលនៅធនាគារពាណិជ្ជ | ១១,០% | ១១,៥% | ៩,៣% |
| បញ្ញើជាដុល្លារនៅធនាគារពាណិជ្ជ | ៦,១% | ៤,៧% | ៤,០% |
| កម្ចីជាដុល្លារនៅធនាគារពាណិជ្ជ | ៩,៤% | ៩,២% | ៨,៤% |
| កម្ចីជារៀលនៅអិល អូ អិល ស៊ី | ១៧,៤% | ១៦,១% | ១៤,៤% |
| កម្ចីជារៀលនៅអម្រឹត | ១៦,៨% | ១៧,៣% | ១៥,៩% |

*ប្រភព៖ ធនាគារជាតិនៃកម្ពុជា*

## ៤) ស្ថានភាពផលិតផលនិងសេវាកម្ម (តារាងទី៤)

➢ ***កសិកម្ម:***

⇨ក្នុងឆ្នាំ២០២៥ ផលិតផលកៅស៊ូមានចំនួន៤២២,៨ពាន់តោន កើនឡើង៣,៨% [YoY]។ ផ្ទៃដីចៀរជ័រមានចំនួន ៣៤៦,៨ ពាន់ហិកតា កើនឡើង៥,០% [YoY] និងផ្ទៃដីដាំដុះសរុបមាន ៤៤៨,១ ពាន់ហិចតាកើនឡើង៥,៣%[YoY] ។

⇨ ផលិតផលជលផលឆ្នាំ២០២៥ មានចំនួន៩៧៨,៦ ពាន់តោនមានការកើនឡើង៥,៧% [YoY]។

- ***ឧស្សាហកម្ម***

⇨ចំនួនរោងចក្រសរុបដែលបានចុះបញ្ជីនៅក្រសួងឧស្សាហកម្មមានចំនួន៣ ០៨៣ រោងចក្រកើនឡើង២៧,១% [YoY]។

⇨ **ការចុះបញ្ជី ការបើកថ្មី និងការបន្ត រោងចក្រ សហគ្រាស**

| *ប្រភេទ* | *ចំនួន :២០២៥* | *ចំនួន:២០២៤* | %∆ |
|---|---|---|---|
| ចំនួនរោងចក្រសរុប | ៣ ០៨៣ | ២ ៤២៥ | ២៧,១% |
| រោងចក្រថ្មី ដែលបានចុះបញ្ជី | ៧០០ | ៣២៦ | ១១៤,៧% |
| ឧស្សាហកម្មធុនតូច និងសិប្បកម្ម (បើកថ្មី) | ១ ២៦២ | ១ ២៩២ | -២,៣% |
| ឧស្សាហកម្មធនតូច និងសិប្បកម្ម (បន្ត) | ១ ៣៦៨ | ១ ៣៣៨ | ២,២% |

*ប្រភព៖ ក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍*

- ***រ៉ែនិងថាមពល:***

⇨ ការផលិតនិងការនាំចូលអគ្គីសនីសរុបក្នុងឆ្នាំ២០២៥មានចំនួន២២ ៣៦១,២ លានKWh កើនឡើង ១២,០% [YoY]។ ក្នុងនោះ៖

| *ប្រភេទ* | *ឯកតា* | អត្រារួមចំណែក | ២០២៥ | ២០២៤ | %∆ |
|---|---|---|---|---|---|
| ប្រភពក្នុងប្រព័ន្ធ | លានKWh | ៩២,១% | ២០ ៥៩៦,១ | ១៨ ៣១៤,៧ | ១២,៥% |
| ក្នុងនោះ: ប្រភពថាមពលស្អាត | លានKWh | ៤៦,១% | ១០ ៣១៧,៥ | ៨ ៥៧៣,៤ | ២០,៣% |
| ប្រភពថាមពលផ្សេងៗ | លានKWh | ៤៦,០% | ១០ ២៧៨,៦ | ៩ ៧៤១,៣ | ៥,៥% |
| ប្រភពនាំចូល | លានKWh | ៧,៩% | ១ ៧៦៥,១ | ១ ៦៥៧,៧ | ៦,៥% |

*ប្រភព៖ ក្រសួងរ៉ែ និងថាមពល*

⇨ ផលិតកម្មស៊ីម៉ងត៍ ក្នុងឆ្នាំ២០២៥ មានចំនួន១០ ៩៣៩,៦ ពាន់តោនមានការ កើនឡើង ២៩,៧% [YoY]។

- **សំណង់ (ការអនុញ្ញាត)**:

សំណង់អនុញ្ញាតឱ្យសាងសង់មានចំនួន២១ ៥៩៥,១ ពាន់ម² មានការកើនឡើង៥៩,៥% [YoY]។ បើគិតជាសាច់ប្រាក់ស្មើនឹង៨ ៥១៤,៩ លានដុល្លារមានការកើនឡើង៤៨,៣% [YoY]។ ក្នុងនោះប្រភេទសំណង់ចម្បងៗមាន:

| *ប្រភេទសំណង់* | ពាន់ម² :២០២៥ | ពាន់ម² :២០២៤ | % ∆ |
|---|---|---|---|
| លំនៅឋាន | ៦ ៨៤២,៥ | ៤ ២៧៦,១ | ៦០,០% |
| ឧស្សាហកម្ម | ១១ ៨៦៩,៤ | ៥ ២៧៧,៩ | ១២៤,៩% |
| ពាណិជ្ជកម្ម | ១ ៦២៤,៣ | ២ ៧៥៧,៥ | -៤១,១% |
| ទេសចរណ៍ | ៧៩៩,៦ | ៤៣៥,៦ | ៨៣,៦% |
| អនុញ្ញាតសរុប | ២១ ៥៩៥,១ | ១៣ ៥៣៦,៨ | |

*ប្រភព៖ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់*

✓ ដូច្នេះសំណង់អនុញ្ញាតដែលពេញនិយមឆ្នាំ ២០២៥ នេះគឺឧស្សាហកម្ម (៥៥%) និងសំណង់លំនៅឋាន (៣២%)។

➢ការចុះបញ្ជីនិងលុបចេញពីបញ្ជី

| ប្រភេទ | ២០២៥ (ចំនួន) | ២០២៤ (ចំនួន) | %Δ |
|---|---|---|---|
| ក្រុមហ៊ុនដែលបានចុះបញ្ជីពាណិជ្ជកម្ម | ៦ ៣៣០ | ៥ ២០១ | ២១,៧% |
| ក្រុមហ៊ុនត្រូវបានលុបចេញពីបញ្ជីពាណិជ្ជកម្ម | ១ ២៦៥ | ១ ២១៤ | ៤,២% |
| សហគ្រាសដែលបានចុះបញ្ជីពន្ធដារ | ៦ ២៧៤ | ៥ ៤២៦ | ១៥,៦% |
| ការស្នើសុំលិខិតអនុញ្ញាត ឬអាជ្ញាបណ្ណតាមប្រព័ន្ធអេឡិចត្រូនិក | ៩១ | ៦៤ | ៤២,២% |
| ក្នុងនោះ លិខិតអនុញ្ញាតសម្រាប់រូបវន្តបុគ្គល | ៤៧ | ២៤ | ៩៥,៨% |

*ប្រភព៖ ក្រសួងពាណិជ្ជកម្ម និងអគ្គនាយកដ្ឋានពន្ធដារ*

➢ ការងារ

| ប្រភេទ | ២០២៥ (នាក់) | ២០២៤ (នាក់) | %Δ |
|---|---|---|---|
| អ្នកចុះឈ្មោះស្វែងរកការងារធ្វើ (ទីភ្នាក់ងារជាតិមុខរបរនិងការងារ) | ១៧៥ ៣៦៩ | ៥០ ៩៩៤ | ២៤៧,៣% |
| អ្នកទទួលការងារធ្វើថ្មីតាមរយៈក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងទីភ្នាក់ងារជ្រើសរើសឯកជន | ៤១៩ ៥៣២ | ៣៣៨ ៩៧៤ | ២៣,៨% |
| អ្នកទទួលបានការងារក្នុងប្រទេស | ៣៩៦ ០៩៧ | ២៩៤ ១១២ | ៣៤,៧% |
| អ្នកទទួលបានការងារក្រៅប្រទេស | ២៣ ៤៣៥ | ៤៤ ៨៦២ | -៤៧,៨% |

*ប្រភព៖ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ*

➢ ***វិនិយោគ**:គម្រោងវិនិយោគអនុញ្ញាតដោយ ក.អ.ក.*

| ប្រភេទ | ២០២៥ | ២០២៤ | %Δ |
|---|---|---|---|
| **អនុញ្ញាតសរុប (លានដុល្លារ)** | ៩ ៩៥៩,១ | ៦ ៨៧២,៤ | ៤៤,៩% |
| វិស័យកសិកម្មនិងកសិឧស្សាហកម្ម | ៤៣៦,១ | ១២០,៥ | ២៦១,៩% |
| វិស័យឧស្សាហកម្ម | ៥ ៥៨៤,៣ | ៤ ៧៥៤,០ | ១៧,៥% |
| (ក្នុងនោះក្នុងតំបន់សេដ្ឋកិច្ចពិសេស) | ២ ៥៣៣,៦ | ២ ៩៩៨,២ | -១៥,៥% |
| វិស័យទេសចរណ៍ | ១៧៥,៣ | ៧៣៨,៩ | -៧៦,៣% |
| វិស័យហេដ្ឋារចនាសម្ព័ន្ធនិងផ្សេងៗ | ៣ ៧៦៣,៤ | ១ ២៥៨,៩ | ១៩៨,៩% |
| **ចំនួនគម្រោងថ្មីនិងពង្រីក (ចំនួន)** | ៦៣០ | ៤១៤ | ៥២,២% |
| **ចំនួនពលករ (ពាន់នាក់)** | ៤៣៨,២ | ៣២៤,៦ | ៣៥,០% |

*ប្រភព៖ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*

➢**សេវាកម្មនិងទេសចរណ៍:**

➢**ទំនិញឆ្លងកាត់កំពង់ផែ**(សរុប២កំពង់ផែ)មានចំនួន១៧ ៨០៨,៩ ពាន់តោនកើនឡើង២៧,៣% [YoY]។ ក្នុងនោះ:

| *ប្រភេទ* | ២០២៥ (ពាន់តោន) | ២០២៤ (ពាន់តោន) | %Δ |
|---|---|---|---|
| កំពង់ផែស្វយ័តក្រុងព្រះសីហនុ | ១២ ២០២,៣ | ៩ ६៥៩,២ | +២៦,៣% |
| កំពង់ផែស្វយ័តភ្នំពេញ | ៥ ६០६,६ | ៤ ៣៣६,០ | +២៩,៣% |
| កុងតឺន័រឆ្លងកាត់កំពង់ផែស្វយ័តក្រុងព្រះសីហនុ | ១ ៣២६,៣ | ១ ០២០,២ | +៣០,០% |
| កុងតឺន័រឆ្លងកាត់កំពង់ផែស្វយ័តភ្នំពេញ | ६០០,០ | ៤៧៨,៣ | +២៥,៤% |

*ប្រភព៖ ក្រសួងសាធារណការ និងដឹកជញ្ជូន*

➢**ការចុះបញ្ជី និងចរាចរណ៍**

ការចុះបញ្ជីម៉ូតូ រថយន្ត និងគ្រោះថ្នាក់ចរាចរណ៍

| *ប្រភេទ* | ២០២៥ (ចំនួន) | ២០២៤ (ចំនួន) | %Δ |
|---|---|---|---|
| ចំនួនម៉ូតូបានចុះបញ្ជី (ពាន់គ្រឿង) | ៤១០,៣ | ៣៤៣,២ | ១៩,६% |
| ចំនួនរថយន្តគ្រប់ប្រភេទបានចុះបញ្ជី(ពាន់គ្រឿង) | ៧៨,៣ | ៥១,६ | ៥១,៨% |
| ចំនួនគ្រោះថ្នាក់ចរាចរណ៍(លើក) | ២ ៣៣៥ | ២ ៨៨៩ | -១៩,២% |

*ប្រភព៖ ក្រសួងសាធារណការ និងដឹកជញ្ជូន*

➢**ប្រៃសណីយ៍និងទូរគមនាគមន៍**

| *ប្រភេទ* | ២០២៥ | ២០២៤ | %Δ |
|---|---|---|---|
| បញ្ញើក្នុងប្រទេស(ពាន់កញ្ចប់) | ១६០,១ | ១៧៣,១ | -៧,៥% - |
| ក្នុងនោះទទួល | ៥៨,០ | ६០,៤ | ៣,៩% |
| បញ្ញើក្រៅប្រទេស(ពាន់កញ្ចប់) | ៣៨១,៨ | ៤៣៣,៩ | -១២,០% |
| ក្នុងនោះទទួល | ២០៣,៤ | ២២៨,៥ | -១១,០% |
| សន្ទនាទូរសព្ទក្នុងប្រទេស(ពាន់នាទី) | ៤ ៥០៧,៨ | ៥ ១៤២,៥ | -១២,៣% |
| ក្នុងនោះហៅចូល | ១ ៥២១,៥ | ១ ៩០១,៤ | -២០,០% |
| សន្ទនាទូរសព្ទក្រៅប្រទេស(ពាន់នាទី) | ២៩ ០៣៣,១ | ១៧ ៨៧២,६ | ६២,៤% |
| ក្នុងនោះហៅចូល | ២៨ ៩១៧,៥ | ១៧ ៧៨៣,६ | ६២,६% |

*ប្រភព៖ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍*

➢**អ្នកដំណើរតាមផ្លូវអាកាស វប្បធម៌ និងទេសចរណ៍**

| *ប្រភេទ* | *ឯកតា* | ២០២៥ | ២០២៤ | %Δ |
|---|---|---|---|---|
| ភ្ញៀវអន្តរជាតិចូលទស្សនាសារមន្ទីរជាតិ | ពាន់នាក់ | ១២៣,៥ | ១២៤,២ | -០,६% |
| ភ្ញៀវទេសចរបរទេសទិញបណ្ណទស្សនាអង្គរ | ពាន់នាក់ | ៩៥៥,១ | ១ ០២៣,៧ | -६,៧% |
| ភ្ញៀវទេសចរបរទេសចូលទស្សនា រមណីយដ្ឋានព្រះវិហារ | ពាន់នាក់ | ៧,៣ | ១៥,៣ | -៥២,១% |
| ភ្ញៀវទេសចរបរទេសចូលទស្សនា រមណីយដ្ឋានកោះកេរ | ពាន់នាក់ | ២६,៩ | ២១,៩ | ២២,៨% |

| | | | | |
|---|---|---|---|---|
| ភ្ញៀវទេសចរបរទេសចូលទស្សនា រមណីយដ្ឋានសំបូរព្រៃគុក | ពាន់នាក់ | ១៧,២ | ១៥,៥ | ១០,៤% |
| អ្នកដំណើរតាមផ្លូវអាកាស (ក្នុងស្រុក) | ពាន់នាក់ | ២៦២,២ | ៣១១,៦ | -១៥,៩% |
| អ្នកដំណើរតាមផ្លូវអាកាស (អន្តរជាតិ) | ពាន់នាក់ | ៦ ៧២៦,១ | ៥ ៩២៤,៨ | ១៣,៥% |
| ទំនិញដឹកជញ្ជូនតាមផ្លូវអាកាស | ពាន់ជើង | ៩៣,៩ | ៧៧,៩ | ២០,៦% |
| ជើងហោះហើររំលងដែនអាកាសកម្ពុជា | ពាន់ជើង | ៨៧,៦ | ៧១,៦ | ២២,៣% |
| អ្នកទេសចរជាតិចេញក្រៅប្រទេស | ពាន់នាក់ | ១ ៣៥៧,៩ | ១ ៨៤៥,៥ | -២៦,៤% |
| ចំនួនទេសចរផ្ទៃក្នុង | ពាន់នាក់ | ២៧ ៣១៩,៨ | ២៦ ៥០៥,៨ | ៣,១% |
| អ្នកទេសចរអន្តរជាតិមកកម្ពុជា | ពាន់នាក់ | ៥ ៥៦៩,៨ | ៦ ៧០០,១ | -១៦,៩% |
| ✓តាមផ្លូវអាកាស | ពាន់នាក់ | ២ ៨៥៧,៧ | ២ ៣៩៦,៩ | ១៩,២% |
| ✓ តាមផ្លូវគោក និងទឹក | ពាន់នាក់ | ២ ៧១២,០ | ៤ ៣០៣,២ | -៣៧,០% |
| កម្រិតគុណភាពខ្យល់នៅកម្ពុជា(PM2.5) | $\mu g/m^3$ | ១៤,២ | ១៧,០ | -១៦,៤% |

*ប្រភព៖ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈរដ្ឋលេខាធិការដ្ឋានអាកាសចរណ៍ស៊ីវិល ,ក្រសួងទេសចរណ៍ , ក្រសួងបរិស្ថាន*

## ៥)ស្ថានភាពពាណិជ្ជកម្ម (តារាង៥)

➡យោងតាមការកត់ត្រារបស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករ ការនាំចូលក្នុងឆ្នាំ២០២៥ មានចំនួន ១៣១ ៦៦៥,១ ប៊ីលានរៀល ស្មើនឹង ៣២ ៨០៩,៦ លានដុល្លារ កើនឡើង១៨,២%[YoY] ។ ក្នុងនោះមាន៖

**តារាង៥.១_ការនាំចូលមុខទំនិញមួយចំនួន**

| បរិយាយ | ឯកតា | ឆ្នាំ ២០២៥ | ឆ្នាំ ២០២៤ | Δ%[YoY] |
|---|---|---|---|---|
| ប្រេងសាំង | ពាន់តោន | ១ ១៣៦,៥ | ១ ១៣១,២ | +០,៥% |
| ប្រេងម៉ាស៊ូត | ពាន់តោន | ១ ៧៧៣,២ | ១ ៧៧៩,៤ | -០,៣% |
| ឧស្ម័ន | ពាន់តោន | ៥១២,៣ | ៤៨៣,៩ | +៥,៩% |
| ដែកសំណង់ | ពាន់តោន | ១ ៣៩៩,០ | ៨២៥,៤ | +៦៩,៥% |
| ស៊ីម៉ង់ត៍ | ពាន់តោន | ២០៨,៣ | ២០៩,៣ | -០,៥% |
| ជីកសិកម្ម | ពាន់តោន | ១ ០២៧,៤ | ៩៥៩,៣ | +៧,១% |
| នាំចូលនៃស្ថានទូតមិនធ្វើអាជីវកម្ម | ប៊ីលានរ | ១៥៦,៧ | ១៤០,១ | +១១,៨% |
| រថយន្តសរុប | ប៊ីលានរ | ៥ ៩៨២,៩ | ៤ ០៦៧,៩ | +៤៧,១% |
| រថយន្តសរុប | គ្រឿង | ៨២ ៥៩៧,០ | ៥២ ២៧៩,០ | +៥៨,០% |
| ត្រាក់ទ័រនិងគោយន្ត | គ្រឿង | ៥១ ៨១៤,០ | ២០ ៧៨៩,០ | +១៤៩,២% |
| ស្រូវសាលី | ពាន់តោន | ១៦៣,១ | ១៩០,៧ | -១៤,៥% |
| ផ្លែឈើនិងបន្លែ | ពាន់តោន | ៣១១,៦ | ៩៥,៣ | +២២៧,០% |
| នាំចូលក្នុងក្របខណ្ឌច្បាប់វិនិយោគ | ប៊ីលានរ | ៣៤ ៤១១,៥ | ៣៣ ២៣១,៦ | +៣,៦% |

*ប្រភព៖ អគ្គនាយកដ្ឋានគយ និងរដ្ឋាករ*

➡ **ការនាំចេញ** ក្នុងឆ្នាំ២០២៥ មានចំនួន១១៤ ៩៧៧,០ប៊ីលានរៀល ស្មើនឹង២៨ ៦៥១,១លានដុល្លារ ( ៨៧,៣% នៃការនាំចូល) កើនឡើង ១៩,១ %[YoY]។ ក្នុងនោះមុខទំនិញសំខាន់ៗមួយចំនួនមាន៖

| ទំនិញ | ឯកតា | ឆ្នាំ ២០២៥ | ឆ្នាំ ២០២៤ | %Δ [YoY] |
|---|---|---|---|---|
| វាយនភណ្ឌនិងស្បែកជើង | ប៊ីលាន៛ | ៦៤ ៤៤២,៩ | ៥៦ ២១៥,២ | +១៤,៦% |
| អង្ករ | ពាន់តោន | ៧៧២,២ | ៦៤៥,៤ | +១៩,៦% |
| ផលិតផលនេសាទ | តោន | ១ ៦០៩,៧ | ៣៤៥,៤ | +៣៦៦,១% |
| កៅស៊ូ | ពាន់តោន | ២៦៦,៤ | ២៧៨,១ | -៤,២% |
| ឱ្យាច់ | ពាន់តោន | ៦៨ ៣៥៥,៧ | ៤៣ ៥៩១,៥ | +៥៦,៨% |
| ស្រូវ | ពាន់តោន | ៦ ៨៥៩,៩ | ៤ ៦០៨,៦ | +៤៨,៩% |
| ដំឡូងមី | ពាន់តោន | ៤ ៦៧០,៤ | ៣ ៧១៩,៧ | +២៥,៦% |
| គ្រាប់ស្វាយចន្ទី | ពាន់តោន | ៦៣៦,៨ | ៥៨៨,៥ | +៨,២% |
| ចេក | ពាន់តោន | ៣៤៣,៦ | ២៦៥,៥ | +២៩,៤% |
| ស្វាយ | ពាន់តោន | ៣២០,៣ | ២៨២,៦ | +១៣,៣% |

*ប្រភព៖ អគ្គនាយកដ្ឋានគយ និងរដ្ឋាករ*

ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស
ប្រធានក្រុមប្រឹក្សាសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌

ទែម គាតរិទ្ធី